

លេខកូដស្ថាប័នផ្ដល់សេវាកម្មអប់រំ
CRICOS provider code 00861K

ជាទីដែលការអប់រំជាការសំខាន់

## រៀបចំអនាគតរបស់អ្នកឲ្យរឹងមាំ នៅក្នុងកម្មវិធីសិស្សអន្តរជាតិ របស់យើងដែលដឹកមុខគេ

# កម្មវិធីសិស្សអន្តរជាតិ

វិទ្យាល័យ Keysborough College មានទីតាំងស្ថិតនៅចំកណ្តាលតំបន់ពហុវប្បធម៌មួយដែលមានជាតិសាសន៍ដ៏ចម្រុះច្រើនបំផុតមួយក្នុងក្រុងមែលប៊ិន។ ស្ថិតនៅជិតសកលវិទ្យាល័យ Monash University, វិទ្យាល័យរបស់យើងមានសេវាកម្មរថយន្តក្រុងដោយផ្ទាល់ ហើយក៏មានភាពងាយស្រួលក្នុងការធ្វើដំណើរទៅទីក្រុងតាមសេវាកម្មរថភ្លើងនៅក្បែរផងដែរ។

ចាប់តាំងពីឆ្នាំ២០០០មក សិស្សអន្តរជាតិជាង១ពាន់នាក់ពីប្រទេសចិន, កម្ពុជា, ឥណ្ឌា, ជប៉ុន, ឡាវ, ស្រីលង្កា, ថៃ និងវៀតណាមបាននាំគ្នាមកសិក្សានៅវិទ្យាល័យ Keysborough College ហើយបានរៀនចប់វិទ្យាល័យដោយជោគជ័យដោយបានចូលទៅរៀនបន្តនៅសកលវិទ្យាល័យ។

ជាសាលារៀនមួយ យើងផ្តល់ជូនសិស្សនូវបរិស្ថានអប់រំដែលមានសុវត្ថិភាព, សន្តិសុខ និងការថែទាំ ដោយមានការផ្តោតការយកចិត្តខ្លាំងលើសមិទ្ធផលរបស់សិស្ស។

KEYSBOROUGH COLLEGE

ការគោរព ឧត្តមភាព ភាពចម្រុះ

អ៊ីមែល៖ keysborough.sc@edumail.vic.gov.au វិបសាយថ៍៖ www.keysboroughsc.vic.edu.au

## ការចូលសិក្សានៅសកលវិទ្យាល័យពីកម្មវិធីសិក្សាទូលំទូលាយ

- បានការចូលទៅរៀននៅសកលវិទ្យាល័យពីមុខវិជ្ជាសិក្សាជាច្រើនទូលំទូលាយ
- សិស្សអន្តរជាតិនៅវិទ្យាល័យ Keysborough College ដែលបានបញ្ចប់ការសិក្សាថ្នាក់ទី១២ដោយជោគជ័យទទួលបានសញ្ញាបត្រអប់រំរដ្ឋវិចថូរៀ (Victorian Certificate of Education - VCE) សម្រាប់ការចូលទៅរៀននៅសកលវិទ្យាល័យ។
- សិស្សអន្តរជាតិជាច្រើនផ្តោតការយកចិត្តទុកដាក់លើមុខវិជ្ជាវិទ្យាសាស្ត្រ, គណិតវិទ្យា, ពាណិជ្ជសាស្ត្រ, ព័ត៌មានវិទ្យា និងមុខវិជ្ជាបន្ថែមជាច្រើនទៀត ដោយផ្តល់លទ្ធភាពឲ្យពួកគេបន្តការសិក្សាលើជំនាញជាច្រើនទៀតដែលពួកគេចាប់អារម្មណ៍។
- សិស្សជាច្រើនដែលបានជោគជ័យ បន្តការសិក្សានៅឯសកលវិទ្យាល័យ Monash University, Melbourne University ឬក៏នៅវិទ្យាស្ថានបច្ចេកទេសបណ្តុះបណ្តាលវិជ្ជាជីវៈ TAFE។

## មជ្ឈមណ្ឌលភាសាអង់គ្លេសនៅក្នុងសាលា

- សិស្សទទួលបានប្រយោជន៍ពីការសិក្សាក្នុងក្រុមតូចៗ ដោយបានការមើលថែទាំពីគ្រូជំនួយភាសាអង់គ្លេស។
- សិស្សអាចចាប់ផ្តើមការសិក្សាភ្លាមៗបាននៅក្នុងបរិស្ថានសាលារៀនរបស់យើង។
- យើងផ្តល់ជូននូវការសម្របខ្លួនចូលរៀនក្នុងវិទ្យាល័យយ៉ាងរលូននៅពេលចាប់ផ្តើមការសិក្សាមុខវិជ្ជាចម្បងៗ។

## ការប្រាស្រ័យទាក់ទងទៀងទាត់ជាមួយមាតាបិតាដើម្បីបានទទួលដំណឹង

- មាតាបិតារបស់សិស្សអន្តរជាតិយើងបានទទួលនូវព័ត៌មានជាហូរហែអំពីការវិវឌ្ឍរបស់កូនប្រុសកូនស្រីរបស់ពួកគេតាមរយៈព្រឹត្តិបត្ររបស់វិទ្យាល័យដែលចេញផ្សាយជាទៀងទាត់ ហើយត្រូវផ្ញើជូនដល់មាតាបិតាសិស្សទាំងអស់។
- មាតាបិតាទាំងអស់ទទួលបាននូវរបាយការណ៍លាយលក្ខណ៍អក្សរដែលបានការបកប្រែភាសារបស់គេអំពីការរីកចម្រើន និងការវិវឌ្ឍរបស់សិស្សរាល់ត្រីមាស។
- ពេញមួយឆ្នាំយើងស្វាគមន៍ និងជំរុញលើកទឹកចិត្តឲ្យមានការប្រាស្រ័យទាក់ទងទៀងទាត់រវាងមាតាបិតាសិស្ស និងវិទ្យាល័យ។
- អ្នកសម្របសម្រួលការងារសិស្សអន្តរជាតិរបស់យើងធ្វើការទាក់ទងដោយផ្ទាល់ជាទៀងទាត់ជាមួយនឹងមាតាបិតាសិស្សដើម្បីឆ្លើយសំណួរចម្ងល់ណាមួយ ឬក៏ផ្តល់ព័ត៌មានសំខាន់ពេលត្រូវការ។
- តំណាងរបស់វិទ្យាល័យរៀបចំការប្រជុំរវាងគ្រូ និងមាតាបិតានៅបរទេសរាល់ឆ្នាំ និងការជួបប្រជុំទល់មុខគ្នាជាមួយនឹងមាតាបិតាសិស្ស។



## រស់នៅដោយមានសន្តិសុខជាមួយក្រុមគ្រួសារអូស្ត្រាលី (Homestay)

- សិស្សអន្តរជាតិរបស់យើងរស់នៅជាមួយក្រុមគ្រួសារអូស្ត្រាលីនៅក្នុងតំបន់ជុំវិញសាលា ដែលបានការជ្រើសរើសដោយប្រុងប្រយ័ត្ន។
- Homestay របស់ក្រុមគ្រួសារអូស្ត្រាលីផ្តល់នូវស្ថិរភាព និងសន្តិសុខជូនដល់សិស្សបរទេសរបស់យើង និងជួយធ្វើឲ្យការស្នាក់នៅរបស់ពួកគេទទួលបាននូវបទពិសោធន៍សប្បាយរីករាយ និងបានស្វែងយល់យ៉ាងល្អប្រសើរអំពីវប្បធម៌អូស្ត្រាលីនៅក្នុងបរិស្ថានគ្រួសារអូស្ត្រាលីដែលមានការគាំពារយកចិត្តទុកដាក់ និងយល់ចិត្ត។

## ផលប្រយោជន៍បានពីការសិក្សាបន្ថែម និងគ្រូជំនួយអប់រំ

### ការជួយបង្រៀនក្រៅម៉ោងសាលាមានជូនដល់សិស្សអន្តរជាតិទាំងអស់ដោយមិនគិតថ្លៃបន្ថែម

- វិទ្យាល័យរបស់យើងមានគ្រូជំនួយអប់រំពហុវប្បធម៌ និងគ្រូជាច្រើនទៀតដែលចេះនិយាយភាសាបរទេសជាភាសាទី២។
- គ្រូជំនួយអប់រំពហុវប្បធម៌មានពេលសម្រាប់សហការយ៉ាងជិតស្និទ្ធជួយដល់សិស្សអន្តរជាតិជាលក្ខណៈបុគ្គលមួយទល់មួយ ឬសម្រាប់ជាក្រុម។ ពួកគេផ្តល់ជូននូវការបង្រៀនបន្ថែមសម្រាប់ការសិក្សារបស់សិស្សម្នាក់ៗ។
- ថ្នាក់រៀនសម្រាប់ជួយបន្ថែមនេះត្រូវបានបង្កើតឡើងដើម្បីដោះស្រាយបញ្ហាតម្រូវការរបស់សិស្សម្នាក់ៗ។
- សិស្សអន្តរជាតិអាចទទួលបាននូវសេវាកម្មដែលមានស្រាប់ជាភាសាកំណើតរបស់ពួកគេនៅគ្រប់កម្រិតនៃការសិក្សា។
- សិស្សអន្តរជាតិទាំងអស់ទទួលបាននូវការជ្រើសរើសមុខវិជ្ជាតាមចំណង់ចិត្ត និងការប្រឹក្សាយោបល់សម្រាប់ជម្រើសការសិក្សាផ្នែកអាជីពទៅថ្ងៃអនាគត។ ពួកគេក៏ទទួលបាននូវជំនួយផងដែរនៅក្នុងការបំពេញឯកសារតម្រូវការនានារបស់ពួកគេ។

## យើងស្វាគមន៍ចំពោះការសួរនាំព័ត៌មានរបស់លោកអ្នក


ចំពោះព័ត៌មានបន្ថែមអំពីកម្មវិធីសិស្សអន្តរជាតិ សូមទាក់ទងលោកស្រី Mrs Mitze Ho ដែលជាអ្នកគ្រប់គ្រងកម្មវិធីសិស្សអន្តរជាតិរបស់យើងតាមរយៈ៖

អ៊ីមែល៖ vlassopoulos.virginia@keysboroughsc.vic.edu.au

ទូរសព្ទ៖ ពីក្នុងស្រុក 03 9546 4144 ( ពីក្រៅស្រុក +613 9546 4144)

ទូរសព្ទចល័ត៖ ពីក្នុងស្រុក 0402 253 332 ( ពីក្រៅស្រុក +61 402 253 332)


